សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

ស.ភ.ន.វ.ស

# នីតិព្រហ្មទណ្ឌពិសេស

I. ឃាតកម្ម

II. ឃាតកម្មគិតទុកជាមុន

III. មនុស្សឃាតដោយអចេតនា

រៀបរៀងដោយៈ

យៀន ប៊ុនហាវ (YEAN BUN HAV)

ថាត ចាន់ថា (THAT CHANTHA)

បណ្ណាល័យច្បាប់-Law Library

lawlibrarysite.wordpress.com

ឆ្នាំសិក្សា

២០១៤~២០១៥

# អារម្ភកថា

ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌមានសារៈសំខាន់ណាស់ចំពោះសង្គម និងរដ្ឋនីមួយៗនៅលើពិភពលោកយើងនេះ ការបង្កើតច្បាប់ព្រហ្មទណ្ឌនេះឡើងគឺដើម្បីឲ្យមនុស្សក្នុងសង្គមចេះគោរពគ្នាទៅវិញទៅមក និង មានការរស់នៅប្រកបដោយសេចក្ដីថ្លៃថ្នូរនិងស្មោះភាព។ ដូច្នេះហើយទើបបណ្ដាប្រទេសនានាជាច្រើន តែងតែយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហាបទល្មើសព្រហ្មទណ្ឌទាំងនេះ ព្រោះថាបទល្មើសព្រហ្មទណ្ឌគឺជា កត្តាដែលធ្វើឲ្យសង្គមមានភាពចលាចល សង្គមគ្មានភាពរីកចំរើនដោយសារតែមនុស្សមិនយល់ដឹងពីច្បាប់ព្រហ្មទណ្ឌនេះ។ ទោះបីប្រទេសនោះខំបង្កើតឲ្យមានច្បាប់ជាច្រើនក៏ដោយ ក៏នៅតែមានមនុស្សមួយចំនួន នៅតែប្រព្រឹត្តខុសនឹងច្បាប់ដដែរ រហូតថែមទាំងប្រព្រឹត្តជាបទល្មើសឧក្រិដ្ឋកម្មនានាជាច្រើនទៀត ។

ឥឡូវច្បាប់ព្រហ្មទណ្ឌនេះ ត្រូវបានគេរឹតបណ្ដឹងក្នុងគោលបំណងសំរាប់ដាក់ទោសទាន់ទៅលើជនណាដែលបានប្រព្រឹត្តបទល្មើសដល់ធ្ងន់ធ្ងរ និងបង្កភាពចលាចលក្នុងសង្គម។ ដូច្នេះហើយ មនុស្សគ្រប់រូបគួរតែនាំគ្នាស្វែងពីច្បាប់ និងសិក្សាពីច្បាប់នានារបស់សង្គម ដើម្បីឲ្យប្រទេសនោះមានភាពរីកចំរើន និងមានធនធានមនុស្សពិតប្រាកដដើម្បីអភិវឌ្ឍន៍ប្រទេស និងយកទៅអនុវត្តន៍នៅក្នុងសង្គមគ្រួសារនីមួយៗរបស់ពួកគេ ជាពិសេសប្រព័ន្ធតុលាការ ឬមន្ត្រីមានសមត្ថកិច្ចត្រូវតែអនុវត្តន៍ច្បាប់ព្រហ្មទណ្ឌនេះឲ្យបានត្រឹមត្រូវគឺមិនត្រូវប្រព្រឹត្តអំពើពុករលួយ ស៊ីសំណូកសូកប៉ាន់ ពីអ្នកមានអំណាច ឬអ្នកមានទឹកលុយទាំងនោះមកគាបសង្កត់រាស្ត្រស្លូតត្រង់ ធ្វើឲ្យច្បាប់របស់ប្រទេសលែងមានប្រសិទ្ធិភាពក្នុងការអនុវត្ត និងគ្មានអ្នកជឿជាក់ទៅលើផ្លូវច្បាប់ និងខូចកិត្តិនាមរបស់ប្រទេស និងរាជរដ្ឋាភិបាលផងដែរ ៕

# សេចក្តីថ្លែងអំណរគុណ

រូបខ្ញុំបានចងក្រងសៀវភៅ ស្តីពីធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌនេះ រហូតបានសម្រេចជាស្ថាពរគឺដោយសារតែគុណបំណាច់របស់លោកសាស្ត្រចារ្យ ជួប ប៊ុនធី ដែលរូបលោកបានខំចំណាយ ពេលវេលាដល់មានតម្លៃនេះមកពន្យល់ណែនាំរូបខ្ញុំបាទ ឲ្យចេះពីរបៀបការរៀបរាងចងក្រងសៀវភៅនេះឡើង។

ជាពិសេសសូមថ្លែងអំណរគុណដល់លោកសាកលវិទ្យាកាល ដែលបានរិះរកគ្រប់មធ្យោបាយ ដើម្បីរកសាស្ត្រចារ្យដ៏ល្បីៗ និងបច្ចេកវិទ្យាទំនើបៗដើម្បីមកបង្ហាត់បង្រៀនដល់រូបខ្ញុំបាទ និង និស្សិតដទៃឲ្យឆាប់យល់ឆាប់ចេះនៅពេលកំពង់សិក្សារបស់ខ្លួន ។

ចុងក្រោយនេះសូមអរគុណមិត្តទាំងអស់ដែលជួយលើកទឹកចិត្ត និងជួយជំរុញឲ្យរូបខ្ញុំខិតខំប្រឹងប្រែង ក្នុងការសិក្សាស្រាវជ្រាវរកឯកសារល្អៗដើម្បីជំនួយក្នុងការសរសេរសៀវភៅនេះ ។

# សេចក្តីផ្តើម

ដោយសារមនុស្សគ្រប់រូបភាគច្រើន មិនសិនយល់ដឹងពីបទល្មើសព្រហ្មទណ្ឌបែបនេះ ហើយ ទើបបណ្តាប្រទេសនៅលើសកលលោក បានបង្កើតច្បាប់ព្រហ្មទណ្ឌនេះឡើង ដើម្បីឲ្យមនុស្សនៅក្នុងសង្គមមិនប្រព្រឹត្តខុសនឹងច្បាប់នេះ និងដើម្បីឲ្យមនុស្សមានការយល់ដឹង និងចេះគោរពគ្នាដោយសេចក្តីថ្លៃថ្នូរ ហើយសង្គមនឹងមានសណ្តាប់ធ្នាប់ សន្តិសុខ និងស្ថេរភាពល្អសំរាប់ការរស់នៅរបស់មនុស្សក្នុងសង្គមនីមួយៗ ចំណែកឯការប្រព្រឹត្តបទល្មើសផ្សេងៗនោះវិញក៏មិនសិនមានធ្ងន់ធ្ងរអ្វីដែរ ឬបើមានក៏មានលក្ខណៈតិចតួចតែប៉ុណ្ណោះ។

ទោះបីជាមានច្បាប់យ៉ាងសំបូរបែបក៏ដោយ ក៏សង្គមមនុស្សនៅតែរំលោភបំពានទៅលើច្បាប់នេះដដែរ។ ហើយធាតុផ្សំនៃការប្រព្រឹត្តបទល្មើសរបស់មនុស្សតែងតែមានជានិច្ច គ្រាន់ថាការប្រព្រឹត្តនោះមានលក្ខណៈទ្រុងទ្រាយតូច ឬធំទៅតាមធាតុផ្សំនៃការប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ។ ពេលខ្លះមនុស្សតែងប្រើធាតុផ្សំនៃការប្រព្រឹត្តនោះ មានដូចជាដំបង កាំបិត ដំថ្ម កាំភ្លើង ឡាន ម៉ូតូ ចារី ឬសហចារី...។

ព្រមទាំងមានស្ថាប័នជាច្រើនដូចជា ស្ថាប័នក្រៅរដ្ឋាភិបាល ក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងលើកស្ទួយ និងពង្រឹងពីច្បាប់ព្រហ្មទ័ណ្ឌនេះ ដើម្បីកុំឲ្យមនុស្សលើលោកនេះប្រព្រឹត្តខុស នឹងច្បាប់របស់សង្គម និងដើម្បីឲ្យមនុស្សគ្រប់រូបយល់ដឹង និងកុំឲ្យមានការរំលោភបំពានទៅលើសិទ្ធិអ្នកដទៃ ដូច្នេះមនុស្សនៅក្នុងសង្គម គួរតែយកចិត្តទុកដាក់ទៅលើច្បាប់ព្រហ្មទណ្ឌនេះ ឲ្យបានល្អទើបសង្គមមានស្ថេរភាពសេរីភាព និងអធិបតេយ្យភាព ហើយប្រទេសនោះបែរឆ្ពោះទៅរកភាពសម្បូរសប្បាយ និងរីកលូតលាស់ទៅជារដ្ឋសម័យទំនើប ។

ប្រជាជននៅបណ្តាប្រទេសទាំងអស់ត្រូវតែចូលរួមទប់ស្កាត់ ពីបទល្មើសព្រហ្មទណ្ឌនេះឲ្យបានតឹងរឹង ហើយមនុស្សនៅក្នុងសង្គមត្រូវតែសិក្សាស្វែងយល់ ឲ្យបានស៊ីជំរៅពីច្បាប់ព្រហ្មទ័ណ្ឌនេះ ដើម្បីកុំឲ្យមនុស្សប្រព្រឹត្តអំពើយ៉ាងឃោរឃៅដាក់គ្នាទៅវិញទៅមកនាំឲ្យអស្ថេរភាព និងខុសច្បាប់សង្គម។ អ្នកគ្រប់គ្រងប្រទេសបានបង្កើតច្បាប់នេះឡើង ដើម្បីការពារ និងសុខុមាលភាពរបស់មនុស្សទាំងប្រុសស្រី ដើម្បីឲ្យមានជីវិតស្រស់ត្រកាល រស់នៅដោយពេញបរិបូរណ៍យ៉ាងល្អប្រសើរឡើងនៅក្នុងពិភពលោកយើងនេះ និងដើម្បីព ង្រឹងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់នានាជាច្រើនទៀត ឲ្យមានប្រសិទ្ធិភាពក្នុងការអនុវត្តច្បាប់របស់ប្រទេសនីមួយ។ ដូច្នេះទើបសង្គមមនុស្សមានស្ថេរភាព និងសម្បូរសប្បាយជាពិសេសសង្គមពិតជាមានមនុស្សមានការចេះដឹង និងសម្បូរទៅដោយធនធានមនុស្សពិត ប្រាកដ ក្នុងការលើកស្ទួយប្រទេសជាតិឲ្យមានភាពរីកចំរើន និង ល្បីល្បាញនៅលើសលកលោកនេះ ៕

# ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ

## I. បទល្មើសឃាតកម្ម

### ១ និយមន័យ

ឃាតកម្ម គឺជាអំពើដែលប្រព្រឹត្តទៅលើក្នុងគោលបំណងដកហូតជីវិតអ្នកដទៃ។

## ២. ធាតុផ្សំនៃបទល្មើសឃាតកម្ម

### ២.១ ធាតុនីត្យានុកូល

មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ចែងថា អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬ មិនប្រើអាវុធ ដោយគ្មានស្ថានទម្ងន់ណាមួយដូចបានកំណត់ក្នុងមាត្រា ២០០ (បទឃាតកម្មគិតទុកជាមុន) ដល់មាត្រា ២០៥ (បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈ) នៃក្រមនេះ គឺជាឃាតកម្ម។ បទឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ។

### ២.២ ធាតុសំភារៈ

-អំពើជាវិជ្ជមានដែលផ្តល់សេចក្តីស្លាប់ដល់មនុស្ស Acte positif de nature a donner la mort ។

-អំពើនេះប្រព្រឹត្តទៅលើជនរងគ្រោះមានភាពជាមនុស្ស Personnalite humaine de la Victime ។

#### ២.២.១ អំពើជាវិជ្ជមានដែលផ្តល់សេចក្តីស្លាប់ដល់មនុស្ស

ជាអំពើជាវិជ្ជមានសម្លាប់មនុស្សដោយប្រើគ្រប់មធ្យោបាយ ដូចជាប្រើកាំភ្លើងបាញ់សម្លាប់ គ្រឿងផ្ទុះ កាំបិត ពូថៅ ច្របាច់ក ច្រានទម្លាក់ពីលើផ្ទះ ពីទីខ្ពស់.....។ល។

អំពើសម្លាប់មនុស្សអាចជាអំពើមួយគត់ ឬដោយមធ្យោបាយជាច្រើនយ៉ាងធ្វើឲ្យស្លាប់ភ្លាម ១ ឬយូរបន្តិចក៏ដោយ អាចប្រព្រឹត្តដោយចារីម្នាក់ ឬដោយចារីច្រើននាក់ ។

- អំពើសម្លាប់ខ្លួនឯង ឬអត្តឃាត មិនអាចជាបទល្មើសត្រូវដាក់ទោសទេ Le suicide nest pas condemnable ។

- អំពើអកម្មខ្លះ ពិតមែនតែនាំអោយមនុស្សសម្លាប់ មិនអាចកំណត់ថាជាបទល្មើសឃាតកម្មទេ ។

ឧទាហរណ៍៖ - បង្អត់អាហារដល់ក្មេងនាំឲ្យស្លាប់

-បង្អត់អាហារជនដែលចាប់បង្ខាំងទុករហូតដល់ស្លាប់

-គ្រូពេទ្យមិនព្យាបាលអ្នកជំងឺ ទុករហូតដល់ស្លាប់

-មិនជួយមនុស្សលង់ទឹកនៅពេលដែលគេមានលទ្ធភាពជួយគ្រប់គ្រាន់

+ អំពើប៉ុនប៉ងសម្លាប់មនុស្សត្រូវមានទោសដូចនឹងឃាតកម្មបានសម្រេចដែរ។

**ចំណាំ៖** *អំពើប៉ុនប៉ងនូកន្លែងនេះគឺសំដៅទៅសកម្មភាពដែលស្តែងចេញដោយមានគោលបំណងយកជីវិតអ្នកដទៃប៉ុន្តែមិនបានសម្រេច ទើបចាត់ទុកជាការប៉ុនប៉ង មានទោសដូចនឹងឃាតកម្ម ។ ហើយចំពោះបុគ្គលដែលមានបំណងសម្លាប់មនុស្សប៉ុន្តែបុគ្គលនោះមិនបានធ្វើសកម្មភាព នោះមិនចាត់ទុកថាមានទោសឡើយ ពីព្រោះបុគ្គលនោះគ្រាន់តែគិតប៉ុណ្ណោះ។*

+ មិនមានបទមនុស្សឃាតដោយចេតនាទេ នៅពេលឃើញជនល្មើសប្រដាប់អាវុធភ្ជង់ទៅលើជនរងគ្រោះ ហើយដោយភ័យខ្លាចខ្លាំងក៏ស្លាប់បន្ទាប់ពីដាច់សរសៃឈាម។

## ២.២.២ ជនរងគ្រោះជាមនុស្សមានជីវិត

ជនរងគ្រោះត្រូវជាមនុស្សមានជីវិត នៅពេលអំពើសម្លាប់បានកើតឡើង ទោះជាមនុស្សចាស់ ជនវិកលចរិក កូនក្មេង ជាអ្នកជំងឺ ដែលហៀបនឹងស្លាប់ក៏ដោយ ។

+ គួរកត់សំគាល់ថា ការសម្លាប់មនុស្សដែលស្លាប់រួចហើយក៏ត្រូវមានទោសដែរ ប៉ុន្តែមិនត្រូវចាត់ទុកជាបទឃាតកម្មឡើយ។

### ៣ ធាតុអត្តនោម័តនៃមនុស្សឃាតដោយចេតនា

ការសើបអង្កេតត្រូវតែរកឲ្យឃើញថា ចារីមានចេតនាឲ្យជនរងគ្រោះស្លាប់ ឬចារីមានសម្បជញ្ញៈដឹងខុសត្រូវលើអំពើរបស់ខ្លួននៅពេលប្រព្រឹត្តបទល្មើស។ ហើយក្នុងករណីអ្នកជំងឺដែលព្យាបាលមិនជា ឬមានជម្ងឺឈឺចុកចាប់ខ្លាំងហួសប្រមាណ- [ ដំបៅមហារីក ] ហើយបានទទួលការសុំអង្វរពីអ្នកជំងឺ ឬសាច់ញាត្តិអ្នកជំងឺអោយធ្វើការចាក់ថ្នាំផ្តាច់ជីវិតរបស់ខ្លួន ឬមធ្យោបាយដទៃទៀត ក៏ដោយក៏ជននោះត្រូវមានទោសដូចនឹងបទឃាតកម្មដែរ។

+ ដូច្នេះចៅក្រមវាយតម្លៃអត្ថិភាពនៃធាតុអត្តនោម័តដោយប្រៀបធៀបទៅនឹងសច្ចធារណ៍ ដែលប្រមូលបាននូវភស្តុតាងសម្លាប់មនុស្ស និងអំពើដែលទុកលទ្ធភាពសម្លាប់មនុស្ស (ការចាក់ កាប់ បាញ់...ទៅលើជនរងគ្រោះ។ល។ ធាតុអត្តនោម័តលេចចេញមកពី ធាតុសត្យានុម័តនៃការសើបអង្កេត តាមការពិនិត្យកត់ហេតុចម្លើយសាក្សីកោសលវិច្ច័យ ។ល។

ចំពោះការសើបអង្កេត មូលហេតុនៃឃាតកម្មសំខាន់ណាស់ដែលត្រូវដឹង ៖

+ ពីព្រោះមូលហេតុទាំងឡាយនោះ បង្កើតបានជាធាតុកំណត់នៅក្នុងការធ្វើអត្តសញ្ញាណកម្មនៃចារី [បទឧក្រិដ្ឋនោះ ផ្តល់ផលប្រយោជន៍ឲ្យអ្នកណា? ]

+ ពីព្រោះមូលហេតុអាចបញ្ជាក់ពីចេតនារបស់ចារី ។

+ ពុំមែនជាឃាតកម្មទេ កាលណាអំពើសម្លាប់មនុស្សបានប្រព្រឹត្តឡើង តាមបញ្ជារបស់អាជ្ញាធរ ឬក្នុងការការពារធម្មានុរូប [ ការពារខ្លួនឯង ឬអ្នកដទៃ ]

## II ឃាតកម្មគិតទុកជាមុន

### ១. និយមន័យ

ឃាតកម្មគិតទុកជាមុនគឺជាអំពើសម្លាប់មនុស្សដោយចេតនា និងមានការគិតទុកជាមុន ឬដោយមានការរៀបចំពួនស្ទាក់ ។

**ចំណាំ៖** *ដូចជាកំពុងប្រវាយប្រតប់គ្នា គូបដិបក្ខម្ខាងសម្លាប់ម្ខាងទៀតតែម្តង ត្រង់ចំនុតនេះមិនត្រូវចាត់ទុកជាបទឃាតកម្មគិតទុកជាមុននោះទេ ដូចនេះគេហៅថា*

*ឃាតកម្ម ។*

# ២ ធាតុផ្សំនៃបទល្មើសឃាតកម្មគិតទុកជាមុន

## ២.១ ធាតុនីត្យានុកូល

ឃាតកម្មគិតទុកជាមុន គឺជាបទឧក្រិដ្ឋមួយដែលច្បាប់ផ្តន្ទាទោសធ្ងន់ជាងគេបំផុត ។ ឃាតកម្មគិតទុកជាមុនបានចែង និងផ្តន្ទាទោសតាមមាត្រា២០០នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ បានចែងថា៖

ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬដោយចេតនាពួនស្ទាក់។

ឃាតកម្មគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។

ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេល ដើម្បីប្រព្រឹត្តអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។

ឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធធានាគារអស់មួយជីវិត។

## ២.២ ធាតុសំភារៈ

បទឃាតកម្មគិតទុកជាមុនជា ស្ថានទម្ងន់ទោសទៅលើបទល្មើសឃាតកម្ម។ ឃាតកម្មគិតទុកជាមុនត្រូវមានធាតុសំភារៈពីរទើបអាចចាត់ទុកជាឃាតិកម្មគិតទុកជាមុនបាន នោះគឺ Aការគិតទុកជាមុន និង B ការពួនស្ទាក់

A ការគិតទុកជាមុន

គឺជាគំរោងការធ្វើឡើងមុនអំពើបៀតបៀនដល់ បុគ្គលណាមួយជាកំណត់ ឬដល់គ្រប់រូបបុគ្គលដែលនឹងជួបប្រទះ ។

ដូច្នេះវាត្រូវតែមានចន្លោះពេលមួយរវាងពេលដែលចារី បានធ្វើការសម្រេចថាប្រព្រឹត្តបទឧក្រិដ្ឋហើយ នឹងពេលដែលគេប្រព្រឹត្តបទឧក្រិដ្ឋនោះ ។

ឧទាហរណ៍ ៖ ការទិញអាវុធសំរាប់ប្រព្រឹត្តបទឧក្រិដ្ឋជាច្រើនថ្ងៃមុនការត្រៀមរៀបចំយ៉ាងហ្មត់ចត់ នៃឃាតកម្ម។ បទល្មើសគិតទុកជាមុន គឺចារីមិនប្រព្រឹត្តក្រោមអំណាចនៃភាពគំរោលភ្លាមដោយសារកំហឹង ឬ ការឈ្នាសនីសការសំអប់ ប៉ុន្តែប្រព្រឹត្ត

ដោយ [ ស្មារតីរឹងប៉ឹងគ្មានតក់ស្លុត ] ដោយការសំរេចចិត្តមុនជាស្រេចរួចទៅហើយ ។ ទោះជាបានគិតទុកជាមុនត្រូវធ្វើឡើងលើរូបបុគ្គលណាមួយជាកំណត់តែបែរជាទៅប្រព្រឹត្តលើរូបបុគ្គលផ្សេងទៀត ក្រៅពីបំណងរបស់ខ្លួនក៏ដោយនោះ ក៏ជាឃាតកម្មគិតទុកជាមុន។

B ការពួនស្ទាក់

គឺជាអំពើសត្យានុម័ត ឃ្លាំចាំជនណាម្នាក់ក្នុងរយៈពេលយូរ ឬចាំនៅកន្លែងណាមួយដើម្បី សម្លាប់ជននោះ ឬប្រព្រឹត្តទៅលើជននោះនូវអំពើហិង្សា ។ ការពួកស្ទាក់ទាមទារអោយមានការគ្រោងទុក ប៉ុន្តែអាចមានការគ្រោងទុកដោយពុំមានការពួនស្ទាក់ទេ។

ឧទាហរណ៍៖ ក្នុងករណីបុរសAមានជំម្លោះជាមួយបុរសBយ៉ាងខ្លាំងខ្លា ហើយបានវាយគ្នា ហើយបុរសA មានការគំគួនទៅលើបុរសB ដោយធ្វើការតាមដានបុរសB ហើយបានដឹងពីផ្លូវទៅផ្ទះរបស់បុរសB ហើយបុរសA បានធ្វើការពួនស្ទាក់នៅតាមផ្លូវដែលបុរសB ធ្វើដំណើរទៅផ្ទះ នៅពេលដែលបុរសB មកដល់កន្លែងដែលបុរសA បានពួនស្ទាក់នោះ បុរសA បានយកកាំបិតចាក់ទៅលើបុរសB បណ្តាលអោយស្លាប់ ដូចនេះសកម្មភាពរបស់បុរសB បានប្រព្រឹត្តនោះជាបទឃាតកម្មគិតទុកជាមុន។

## ២.៣ ធាតុអត្តនោម័ត

- ដូចគ្នានឹងឃាតកម្មដែរ គឺការសើបអង្កេតត្រូវតែរកឲ្យឃើញថា ចារីមានចេតនាឲ្យជនរងគ្រោះស្លាប់ដោយមានការគិតទុកជាមុន ឬចារីមានសម្បជញ្ញៈដឹងខុសត្រូវលើអំពើរបស់ខ្លួននៅពេលប្រព្រឹត្តបទល្មើស។

+ ដូច្នេះចៅក្រមវាយតម្លៃអត្ថិភាពនៃធាតុអត្តនោម័តដោយប្រៀបធៀបទៅនឹងសច្ចធារណ៍ ដែលប្រមូលបាននូវភស្តុតាងសម្លាប់មនុស្ស និងអំពើដែលទុកលទ្ធភាពខ្ពស់ក្នុងការសម្លាប់មនុស្ស (ការចាក់ កាប់ បាញ់...សំដៅទៅរកកន្លែងសំខាន់ដែលទុកនូវលទ្ធភាពនៃការស្លាប់ច្រើន ដូចជាបេះដូងជាដើម)។ល។ ធាតុអត្តនោម័តលេចចេញមកពី ធាតុសត្យានុម័តនៃការសើបអង្កេត តាមការពិនិត្យកត់ហេតុចម្លើយសាក្សី កោសលវិច្ឆ័យ ។ល។

ឧទាហរណ៍ ៖ ឈ្មោះ ក បានគិតទុកជាមុនជាស្រេចថា សម្លាប់ ខ ដោយខ្លួនមានទំនាស់គ្នាជាច្រើនថ្ងៃមកហើយ។ ឈ្មោះ ក បានគាស់បង្អួចចូលទៅបាញ់

ឈ្មោះ ខ នៅពេលយប់ គឺបាញ់សំដៅយកគ្រែតែម្តង តែជួនពេលនោះឈ្មោះ ខ មិននៅផ្ទះ តែបានរៀបចំគ្រែដូចមាននមនុស្សដេកដែរ ។ នោះគឺ អំពើប៉ុនប៉ងធ្វើឃាតកម្មដោយគិតទុកជាមុន ព្រោះមានការបង្ហាញឡើងនូវ ចេតនាសម្លាប់មនុស្សរួចជាស្រេចទៅហើយ ។

## III មនុស្សឃាតដោយអចេតនា

មនុស្សឃាតដោយអចេតនា ជាអំពើបង្កការស្លាប់ដល់មនុស្សម្នាក់ ដោយពុំមានបំណងធ្វើអោយគេស្លាប់ ត្រូវបានផ្តល់លក្ខណ:ជាមនុស្សឃាតដោយអចេតនា ។

### ១. ធាតុនីត្យានុកូល

មនុស្សឃាតដោយអចេតនាត្រូវបានចែង និងផ្តន្ទាទោសដោយមាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

បទមនុស្សឃាតដោយអចេតនា គឺជាអំពើបណ្តាលឱ្យស្លាប់អ្នកដទៃដោយៈ

១. ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬ ការខ្ជីខ្ជា។

២. ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬ កាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។

បទមនុស្សឃាតដោយអចេតនា ត្រូវផ្តន្ទាសទោសដាក់ពន្ធធានាគារពី១ ឆ្នាំ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០រៀល ទៅ ៦.០០០.០០០រៀល។

### ២. ធាតុសត្យានុម័ត

មាត្រា ២០៧ បានគ្រោងករណី ៣យ៉ាងខុសៗគ្នា ៖

+ ការមិនប្រុងប្រយ័ត្ន គឺ អំពើមិនបានធ្វើការប្រុងប្រយ័ត្នដែលចាំបាច់ អំពើឥតគំនិត មិនប្រយ័ត្នជាមុន ។

ឧទាហរណ៍៖ ការគ្រោះថ្នាក់ដល់ជីវិត[ ដល់ស្លាប់ ] ដោយសារតែការថែទាំយានយន្តមិនបានល្អ ។

+ ការធ្វេសប្រហែស គឺជាការភ្លេច ធ្វើការប្រុងប្រយ័ត្ន ដែលគោរពតាមការប្រុងប្រយ័ត្ននេះ អាចនឹងបង្ការនូវគ្រោះថ្នាក់ និងជៀសវាងបាននូវការស្លាប់ ដល់អ្នករងគ្រោះ ។ សេចក្តីខ្ជិលច្រអូសការរាយមាយ ឬអំពើមាក់ងាយជារឿយៗ គឺជាប្រភពនៃការធ្វេសប្រហែស ។

ឧទាហរណ៍ ៖ ១. ឱសថការីដែលប្រគល់ថ្នាំដែលមានជាតិពុលដោយច្រឡំ ទៅអោយអ្នកទិញថ្នាំហើយអ្នកទិញបានលេបហើយបណ្តាលអោយស្លាប់។

២. សហាគ្រិនដែលមិនធ្វើការប្រុងប្រយ័ត្នដើម្បីការពារ និង បំភ្លឺគំនរថ្ម និងរណ្តៅនៅតាមវិថី ហើយបណ្តោយអោយធ្វើដំណើរធ្លាក់ចូលក្នុងរណ្តៅបណ្តាលអោស្លាប់។

## ៣ ធាតុអត្តនោម័ត

ផ្ទុយនឹងមនុស្សឃាតដោយចេតនា ក្នុងករណីមនុស្សឃាតដោយអចេតនា ពុំមានចេតនា បង្កឲ្យមានការស្លាប់នោះទេ [ កំហុសដោយអចេតនា ] ។

ត្រង់នេះកំហុសបានកើតឡើងដោយសារការមិនប្រុងប្រយ័ត្ន ការធ្វេសប្រហែស និងការ ឆ្គាំ ឆ្គង ់ ។ ជាអំពើមិនបានប្រុងប្រយ័ត្នដែលចាំបាច់ ដើម្បីជៀសវាង ការគ្រោះថ្នាក់ និងផលវិបាក ទាំងឡាយរបស់វា ។

# សន្និដ្ឋាន

ទោះបីប្រទេសនីមួយៗបានចងក្រងបង្កើតច្បាប់ ក្នុងគោលបំណងដើម្បីការពារការរំលោភបំពាន លើ សិទ្ធិ របស់អ្នកដទៃក៏ដោយ ប៉ុន្តែផ្ទុយទៅវិញច្បាប់នេះហាក់ដូចជាពុំមានប្រសិទ្ធភាពក្នុងការអនុវត្តនោះទេ ។ ហេតុនេះហើយទើបសព្វថ្ងៃនេះការរំលោភបំពានរបស់មនុស្សក្នុងសង្គមនៅតែបង្កលក្ខណៈលំបាកដ៏សង្គមដដែរ និងធ្វើឲ្យមនុស្ស រងទុក្ខវេទនា និងអស្ថេរភាពសព្វបែបយ៉ាងដែលជាទង្វើបង្កឡើងដោយសារពួកមនុស្ស គ្មាន ការពិចារណា និងខ្វះការអប់រំទើបបណ្តាលឲ្យមានភាពមិនរីកចំរើននៅក្នុងប្រទេស ។

រូបភាពជាក់ស្តែងនៅប្រទេសកម្ពុជាយើងនេះ គឺ ការគោរពច្បាប់ និង ការអនុវត្ត នៃច្បាប់នៅមាន កម្រិត ទាប នៅឡើយ។បើយើងសង្កេតមើលទៅលើច្បាប់នៅប្រទេសកម្ពុជាវិញនោះយើងឃើញថា ការប ង្កើត ច្បាប់ គឺមានច្រើនសណ្ឋានណាស់ ចុះហេតុអ្វីក៏ប្រទេសខ្មែរនៅតែមានភាពអសន្តិសុខដដែរ។ ពេលខ្លះមិនថា អ្នកក្រ ឬអ្នកមានទឹកលុយ អ្នកមានឋានៈ និងអំណាច ឬអ្នកអាងខ្សែខ្នងធំៗ ជាពិសេសមន្ត្រីក្នុង រដ្ឋា ភិបាល គ្រប់លំដាប់ថ្នាក់មួយចំនួន មិនបានគោរពប្រតិបត្តិឲ្យបានត្រឹមត្រូវនៃច្បាប់របស់ប្រទេសនេះទេ គឺមានតែការ រំលោភបំពាន និងប្រព្រឹត្តអំពើពុករលួយ ដោយល្មើសលើផ្លូវច្បាប់ដដែរ ។

ករណីខាងលើនេះ គួរតែរាជរដ្ឋាភិបាលយកចិត្តទុកដាក់ និងមានវិធានការទប់ស្កាត់ ឬរកដំណោះ ស្រាយ អំពីបញ្ហាការរំលោភបំពាន និងមិនខ្លាចក្រែងនៃច្បាប់ប្រទេសនេះឲ្យបានមឹងម៉ាត់ត្រឹមត្រូវយុត្តិធម៌ ទៅ តាមរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិ ដើម្បីឲ្យសង្គមមនុស្សមានស្ថេរភាពល្អ និងភាពរីកចំរើន ៕

# អំណរអំណរគុណ

សៀវភៅនេះរូបខ្ញុំពិតជាបាន ចងក្រងឡើងដោយស្នាដៃរបស់ខ្ញុំផ្ទាល់មែន ។ ហើយរូប ខ្ញុំបានខិតខំសិក្សាស្រាវជ្រាវរកឯកសារយ៉ាងល្អៗដើម្បីបញ្ចូលទៅក្នុងសៀវភៅនេះ ឲ្យមានន័យគ្រប់គ្រាន់ និងទុកសំរាប់ឲ្យ និស្សិតជំនាន់ក្រោយដែលបានមកសិក្សានៅសាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យានេះ បានស្គាល់ និងអាន ពីស្នាដៃរបស់ យើងផង និងធ្វើការស្រាវជ្រាវបន្តទៅទៀត នៅចន្លោះខ្វះខាតរបស់ខ្ញុំបាទ។

# ឯកសារយោង

១. ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី ៣០ ខែវិច្ឆកា ឆ្នាំ២០០៩

២. សៀវភៅនីតិព្រហ្មទណ្ឌទូទៅ លោកគ្រូ រុទ្ធ ពណ្ណារិទ្ធ

៣. សៀវភៅនីតិព្រហ្មទណ្ឌទូទៅខ្មែរ លោក កៅ សីហា